# ប្រសាសន៍របស់ឯកឧត្តមទេសាភិបាលធនាគារជាតិនៃកម្ពុជា



ខ្ញុំមានសេចក្តីសោមនស្សរីករាយផ្សព្វផ្សាយព្រឹត្តិបត្រស្ថិតិជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០០៦ ។ ព្រឹត្តិបត្រប្រចាំត្រីមាសទី១ ឆ្នាំ២០០៦ ដែលលោក លោកស្រី កំពុងមានក្នុងដៃនេះ ជាព្រឹត្តិបត្រដែលរៀបចំនិងចេញផ្សាយលើកទី១១ ដោយធនាគារជាតិនៃកម្ពុជា ។

ការចេញផ្សាយនេះមានសេចក្តីលំអិតអំពីស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិ ក្នុងអំឡុងឆ្នាំ២០០៣ ដល់ឆ្នាំ២០០៤ និងទិន្នន័យពីត្រីមាសទី១ ឆ្នាំ២០០៥ ដល់ត្រីមាសទី១ ឆ្នាំ២០០៦ ។

ស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់ប្រទេសកម្ពុជា ត្រូវបានចងក្រងឡើងដោយផ្អែកតាមវិធីសាស្រ្តចងក្រងស្ថិតិជញ្ជីងទូទាត់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (បោះពុម្ពលើកទី៥) ក្នុងគោលបំណងផ្តល់ព័ត៌មានស្តីពីការវិវត្តន៍ថ្មីៗនៃស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់ប្រទេសកម្ពុជា ដោយរាប់បញ្ចូលការប្រែប្រួលក្នុងខ្ទង់គណនីចរន្ត និងខ្ទង់គណនីដើមទុននិងហិរញ្ញវត្ថុ ព្រមទាំងការប្រែប្រួលខ្ទង់ទ្រព្យសកម្មបរទេស និងទ្រព្យអកម្មបរទេស ។ សេចក្តីអធិប្បាយសង្ខេបអំពីប្រភព និងវិធីសាស្រ្តទាំងឡាយដែលប្រើប្រាស់ក្នុងការចងក្រងស្ថិតិទាំងនេះ មានបង្ហាញក្នុង **"កំណត់បង្ហាញបច្ចេកទេស"** នៅផ្នែកខាងចុងនៃព្រឹត្តិបត្រនេះ ។

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងព្យាយាមធ្វើឱ្យប្រសើរឡើងនូវការចងក្រង និងបន្តកម្មវិធីកែលំអគុណភាពស្ថិតិទាំងនេះ ។ អាស្រ័យហេតុនេះ យើងខ្ញុំសូមស្វាគមន៍ចំពោះរាល់មតិនិងសំណូមពរកែលំអលើការចេញផ្សាយខ្លឹមសារ និងការរៀបចំដើម្បីឱ្យការចេញផ្សាយលើកក្រោយៗទៀតអាចបម្រើតម្រូវការរបស់អ្នកប្រើប្រាស់កាន់តែល្អជាងមុន ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះការចាប់អារម្មណ៍របស់អ្នកអានទាំងអស់លើព្រឹត្តិបត្រស្ថិតិជញ្ជីងទូទាត់ និងស្ថានភាពវិនិយោគអន្តរជាតិរបស់ប្រទេសកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៦

ជា ចាន់តូ

# មាតិកា

ទំព័រ


កំណត់សំគាល់.......................................................................................................៥

ផ្នែកសំខាន់ៗ .......................................................................................................៧

សមាសភាគជាគន្លឹះ .............................................................................................៧

ចំណុចគន្លឹះ ......................................................................................................៧

រូបទី១ : សមាសភាគគណនីចរន្ត.......................................................................៧

រូបទី២ : គណនីដើមទុននិងហិរញ្ញវត្ថុ.................................................................៨

រូបទី៣ : សមាសភាគស្ថានភាពវិនិយោគអន្តរជាតិ...................................................៨

ការពិភាគលើការទូទាត់ស្ថាន.................................................................................៨

គណនីចរន្ត.........................................................................................................៨

រូបទី៤ : ការនាំចេញនិងការនាំចូល.....................................................................៩

រូបទី៥ : សេវា (ឥណទាននិងឥណពន្ធ).............................................................៩

រូបទី៦ : ប្រាក់ចំណូល (ឥណទាននិងឥណពន្ធ)...................................................១០

រូបទី៧ : បង្វែរចរន្ត (ឥណទាននិងឥណពន្ធ).....................................................១១

គណនីហិរញ្ញវត្ថុ..................................................................................................១១

រូបទី៨ : សមាសភាគគណនីហិរញ្ញវត្ថុ.................................................................១១

ស្ថានភាពវិនិយោគអន្តរជាតិ..................................................................................១២

ជញ្ជីងទូទាត់របស់ប្រទេសកម្ពុជា...........................................................................១៨

តារាងទី១ : តារាងសង្ខេបជញ្ជីងទូទាត់...................................................................១៩

តារាងទី២ : គណនីទំនិញ......................................................................................២០

តារាងទី៣ : គណនីសេវា........................................................................................២១

តារាងទី៤ : គណនីប្រាក់ចំណូល..............................................................................២២

តារាងទី៥ : គណនីបង្វែរចរន្ត.................................................................................២៣

តារាងទី៦ : គណនីបង្វែរដើមទុន.............................................................................២៤

តារាងទី៧ : គណនីហិរញ្ញវត្ថុ..................................................................................២៥

តារាងទី៨ : ស្ថានភាពវិនិយោគអន្តរជាតិ...................................................................២៦

តារាងទី៩ : បំណុលក្រៅប្រទេស..............................................................................២៧

តារាងទី១០: អនុបាតជញ្ជីងទូទាត់...........................................................................២៨

កំណត់បន្ទាញបច្ចេកទេស.......................................................................................២៩

## កំណត់សំគាល់ :

**ការសាកសួរព័ត៌មាន**

ចំពោះព័ត៌មានបន្ថែមអំពីស្ថិតិជញ្ជីងទូទាត់ និងស្ថិតិដែលពាក់ព័ន្ធ សូមទាក់ទងលោក **តាន់ សុខាន់** អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងស្ថិតិ នៃធនាគារជាតិនៃកម្ពុជា តាមទូរស័ព្ទលេខ : (៨៥៥) ១៦ ៧៧៥ ៧៩៩។

**ការចេញផ្សាយលើកក្រោយ**

| ការចេញផ្សាយ | ពេលវេលាចេញផ្សាយ |
| --- | --- |
| ត្រីមាសទី២ ឆ្នាំ២០០៦ | ខែកញ្ញា ឆ្នាំ២០០៦ |

**ការកែប្រែក្នុងការចេញផ្សាយលើកនេះ**

**ចំណែ :**

ការចេញផ្សាយលើកនេះ មានរាប់បញ្ចូលការកែតម្រូវខ្ទង់ទិន្នន័យនាំចេញ និងនាំចូល ចាប់ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៥ គឺដោយសារ (១) ការដាក់បញ្ចូលបន្ថែមទិន្នន័យថ្មីៗ (២) ការកែតម្រូវប្រភពផ្តល់ទិន្នន័យ (៣) ការដាក់បញ្ចូលលទ្ធផលអង្កេតថ្មីៗ (៤) ការប្តូរវិធីសាស្ត្រចងក្រងដើម្បីធ្វើឱ្យត្រូវគ្នានឹងទិន្នន័យរបស់ប្រទេសជាដៃគូពាណិជ្ជកម្ម។ ការកែតម្រូវនេះ បណ្តាលឱ្យមានការកែតម្រូវទិន្នន័យពាក់ព័ន្ធមួយចំនួនដូចជា ទិន្នន័យសេវាដឹកជញ្ជូនតាមផ្លូវទឹក ទិន្នន័យសេវាធានារ៉ាប់រងក្នុងសេវាផ្សេងៗនៃគណនីសេវា និងទិន្នន័យឥណទានពាណិជ្ជកម្មនៃគណនីវិនិយោគផ្សេងទៀត ។

ការកែតម្រូវទិន្នន័យគណនីសេវា ចាប់ពីឆ្នាំ២០០៣ តរៀងមក គឺដោយសារការដាក់បញ្ចូលបន្ថែមទិន្នន័យថ្មី ដែលស្រង់បានពីប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) ។

ទិន្នន័យគណនីបង្វែរចរន្ត និងបង្វែរដើមទុន (ឥណទាន និងឥណពន្ធ ) ត្រូវបានកែតម្រូវដោយដាក់បញ្ចូលបន្ថែមទិន្នន័យថ្មី ដែលស្រង់បានពីប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (ITRS) ចាប់ពីឆ្នាំ២០០៣ តរៀងមក និងការធ្វើបច្ចុប្បន្នកម្មលំហូរជំនួយបរទេស និងបំណុលរដ្ឋាភិបាលសម្រាប់ឆ្នាំ២០០៥។ ការកែតម្រូវទិន្នន័យទាំងនេះ បណ្តាលឱ្យមានការកែប្រែសមតុល្យគណនីចរន្ត និងសមតុល្យគណនីដើមទុននិងហិរញ្ញវត្ថុ។

ការកែតម្រូវក៏បានធ្វើឡើងផងដែរចំពោះខ្ទង់ទិន្នន័យស្ថានភាពវិនិយោគអន្តរជាតិ និងខ្ទង់ទិន្នន័យបំណុលក្រៅប្រទេស ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥។ ការកែតម្រូវនេះគឺដើម្បីដាក់បញ្ចូលទិន្នន័យថ្មីៗចុងក្រោយ ដែលទើបទទួលបានពីប្រភពផ្តល់ទិន្នន័យ ជំនួសឱ្យការចេញផ្សាយខ្ទង់ទិន្នន័យទាំងនេះកាលពីលើកមុន។

**ការកែប្រែក្នុងការចេញផ្សាយលើកក្រោយ**

ទិន្នន័យចំណូលពីការវិនិយោគផ្ទាល់បរទេស និងគណនីហិរញ្ញវត្ថុ អាចនឹងមានការកែតម្រូវដោយផ្អែកតាមគំរូប៉ាន់ស្មានថ្មីដែលបាននិងកំពុងអភិវឌ្ឍ ហើយនឹងដាក់បញ្ចូលលទ្ធផលនោះក្នុងការចេញផ្សាយលើកក្រោយ ។

**អក្សរកាត់**

| | |
| --- | --- |
| BOP | ជញ្ជីងទូទាត់ |
| ITRS | ប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| n.i.e | មិនមានរាប់បញ្ចូលនៅកន្លែងផ្សេងទៀត |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |

**ការតម្រឹមតួលេខ**

ភាពខុសចន្លោះដោយអន្លើរវាងចំនួនសរុប និងផលបូកក្នុងការបោះពុម្ពផ្សាយ លើកនេះបណ្តាលមកពីការតម្រឹមតួលេខ ។

**ព័ត៌មានលំអិតបន្ថែមទៀត**

ចំពោះព័ត៌មានលំអិតបន្ថែមទៀត និងសេវាទិន្នន័យពិសេសអាចសាកសួរតាមសំណូមពរ ឬតាមការមកជាវព្រឹត្តិបត្រដោយផ្ទាល់ ។

សំរាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងនាយកដ្ឋាន ស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ ធនាគារជាតិ នៃ កម្ពុជា
ទូរស័ព្ទ : ០២៣ ៧២២ ២២១ រួចភ្ជាប់ទៅលេខ ១០៧៤
អ៊ីមែល: info@nbc.org.kh